# កំណត់ហេតុ

# វេទិកាសិក្សាលើកទី ១

# ស្តីពី

# ការឆ្លុះបញ្ចាំងអំពីការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាន ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងនិរន្តរភាព

**ថ្ងៃទី ០៧-០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង**

| | |
|---|---|
| សម្របសម្រួលដោយ៖ | កញ្ញា កៅ ពៅលក្ខិណា<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ពិធីករ៖ | កញ្ញា កៅ ពៅលក្ខិណា |
| អ្នកកត់ត្រា៖ | កញ្ញា កៅ ពៅលក្ខិណា |
| ចូលរួមដោយ៖ | អង្គការសហគមន៍មូលដ្ឋាន៖ ៤៩<br>អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក៖ ០៦<br>អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា៖ ០៥<br>សរុបសិក្ខាកាម៖ ៦០នាក់<br>(សូមមើលឧបសម្ព័ន្ធ ១ សម្រាប់បញ្ជីវត្តមានសម្រាប់ទាំងពីរថ្ងៃ) |
| ថ្ងៃ ខែ ឆ្នាំ និងពេលវេលា៖ | ០៧ –០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ចាប់ពីម៉ោង ០៨៖០០ ព្រឹក – ០៥៖០០ល្ងាច |
| ទីកន្លែង៖ | សណ្ឋាគារខេមរា ខេត្តបាត់ដំបង |

## គោលដៅនៃវេទិកាសិក្សា៖

វេទិកាសិក្សានេះមានគោលដៅចំបងធំៗគឺ៖



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃទំនុកចិត្ត

១. ដើម្បីធ្វើការឆ្លុះបញ្ចាំង និងទទួលយកយោបល់ត្រលប់ពីសិក្ខាកាម ដែលបានចូលរួមវគ្គបណ្តុះបណ្តាលកន្លងមក បានយកចំណេះដឹងនេះទៅអនុវត្តក្នុងអង្គការសហគមន៍មូលដ្ឋាន និងអភិវឌ្ឍសហគមន៍របស់គាត់បានដល់កម្រិតណា

២. ដើម្បីផ្តល់ឱកាសដល់អង្គការសហគមន៍មូលដ្ឋានក្នុងការពិភាក្សាស្វែងរកការវិធីសាស្រ្តល្អមួយដើម្បីនិរន្តរភាពសម្រាប់សហគមន៍ពួកគាត់

៣. ដើម្បីប្រើប្រាស់នូវយោបល់ត្រលប់ពីអ្នកចូលរួម ដែលអាចធ្វើអោយប្រសើរថែមទៀតនូវការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាន

៤. ដើម្បីបន្តការផ្សព្វផ្សាយសៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជា

(សូមមើលឧបសម្ព័ន្ធ ២ សម្រាប់ឯកសារទស្សនទាន និងរបៀបវារៈ)

## I- លទ្ធផលនៃវេទិកាសិក្សា

### ការណែនាំអំពីគោលបំណងនៃវេទិកាសិក្សារបស់អង្គការសហគមន៍មូលដ្ឋាន ដោយកញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

កញ្ញាបានណែនាំពីគោលបំណង និងរបៀបវារៈនៃវេទិកាសិក្សារបស់អង្គការសហគមន៍មូលដ្ឋាន និងអញ្ជើញលោក ទុំ វីរ៉ា នាយកប្រតិបត្តិ អង្គការមនុស្សចាស់កម្ពុជា ថ្លែងសន្ទរកថាស្វាគមន៍។

### សន្ទរកថាស្វាគមន៍ ដោយលោក ទុំ វីរ៉ា នាយកប្រតិបត្តិ ដែលជានាយកប្រតិបត្តិមកពីអង្គការមនុស្សចាស់កម្ពុជា

លោក ទុំ វីរ៉ា បានថ្លែងអំណរគុណដល់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាដែលបានផ្តួចផ្តើមបង្កើតវេទិកាសិក្សានេះ និងអង្គការមនុស្សចាស់កម្ពុជា រីករាយក្នុងការចូលរួមសហការរៀបចំវេទិកាសិក្សានេះ ព្រោះវាជាឱកាសដែលអង្គការសហគមន៍មូលដ្ឋានដែលមកពីបណ្តាខេត្តនៅតាមតំបន់ភាគពាយព្យ រួមមាន ខេត្តបាត់ដំបង សៀមរាប និងពោធិ៍សាត់ ជួបជុំគ្នា សិក្សា ពិភាក្សាផ្លាស់ប្តូរយោបល់រវាងគ្នា និងគ្នា។ អង្គការសហគមន៍មូលដ្ឋានមានច្រើននៅតាមគ្រប់ភូមិទាំងអស់ តែសមត្ថភាពរបស់ពួកគាត់មួយចំនួននៅមានកម្រិត ហើយលោកសង្ឃឹមថាអង្គការសហគមន៍មូលដ្ឋានដែលបានចូលរួមក្នុងវេទិកានេះនឹងចាប់យកឱកាសនេះសិក្សា និងក្រេបយកចំណេះដឹងដើម្បីយកទៅអភិវឌ្ឍន៍អង្គការសហគមន៍មូលដ្ឋានរៀងៗខ្លួន ព្រោះថាអង្គការសហគមន៍មូលដ្ឋានដើរតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍសហគមន៍។

### សន្ទរកថាស្វាគមន៍ ដោយលោក សៀង សារឿន នាយកប្រតិបត្តិ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

លោកចាប់ផ្តើមសន្ទរកថាដោយថ្លែងអំណរគុណដល់សិក្ខាកាមទាំងអស់ដែលបានចូលរួមក្នុងវេទិកាសិក្សានេះ ហើយក៏បានថ្លែងអំណរគុណផងដែរដល់អង្គការទាំងប្រាំដែលបានចូលរួមសហការរៀបចំ។ អង្គការទាំងនោះរួមមាន៖



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃទំនុកចិត្ត

អង្គការបន្ទាយស្រី សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល អង្គការមនុស្សចាស់កម្ពុជា អង្គការពន្លឺកុមារ និងអង្គការក្រុមទ្រទ្រង់ភូមិ។ លោកបានរំលឹកឡើងវិញអំពីស្មារតីសន្ធិសញ្ញាទីក្រុងប៉ារីស និងសារៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ លោកក៏បានលើកទឹកចិត្តក្នុងការធ្វើការរួមគ្នារវាងអង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងវិស័យឯកជន។ លោកសង្ឃឹមថាវេទិកាសិក្សារយៈពេលពីរថ្ងៃនេះនឹងមានការចូលរួមយ៉ាងសកម្មពីសំណាក់សិក្ខាមទាំងអស់ក្នុងការពិភាក្សា និងធ្វើការឆ្លុះបញ្ចាំងអំពីការប្រតិបត្តិ និងស្វែងរកធនធានដែលមាននៅក្នុងសហគមន៍ ដើម្បីរកចំណូល និងនិរន្តរភាពដល់សហគមន៍។

## បទបង្ហាញអំពី «គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន» ដោយកញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

កញ្ញាធ្វើបទបង្ហាញអំពីខ្លឹមសារ ដែលមាននៅក្នុងសៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ដោយចាប់ផ្តើមពីដំណើរការ ការសម្របសម្រួល និងការចូលរួមរៀបចំបង្កើតគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋានពីសំណាក់ក្រុមការងារបច្ចេកទេស និងការបង្រៀនសាកល្បងទៅដល់អង្គការសហគមន៍មូលដ្ឋាន។ បន្ទាប់មកធ្វើបទបង្ហាញអំពីគោលបំណងនៃការបង្កើតគោលការណ៍ណែនាំ និងជំពូកទាំង ០៨ និងឧបសម្ព័ន្ធគម្រូះ

១. ជំពូកទី ១៖ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន
- ឧបសម្ព័ន្ធគម្រូ ១៖ លក្ខន្តិកៈនៃអង្គការសហគមន៍មូលដ្ឋាន

២. ជំពូកទី ២៖ ទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ
- ឧបសម្ព័ន្ធគម្រូ ២៖ ការសម្របសម្រួលកិច្ចប្រជុំប្រកបដោយប្រសិទ្ធភាពសម្រាប់អង្គការ

៣. ជំពូកទី ៣៖ សមាជិកភាព និងការគ្រប់គ្រងសមាជិក

៤. ជំពូកទី ៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ
- ឧបសម្ព័ន្ធគម្រូ ៣៖ គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ

៥. ជំពូកទី ៥៖ គណនេយ្យភាព និងតម្លាភាព
- ឧបសម្ព័ន្ធគម្រូ ៤៖ គោលការណ៍បង្ការទំនាស់ផលប្រយោជន៍
- ឧបសម្ព័ន្ធគម្រូ ៥៖ ទម្រង់ផ្តល់ព័ត៌មានត្រលប់ ឬបណ្តឹងតវ៉ា

៦. ជំពូកទី ៦៖ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ
- ឧបសម្ព័ន្ធគម្រូ ៦៖ ទម្រង់បញ្ជីតាមដាន និងត្រួតពិនិត្យ ផែនការសកម្មភាព

៧. ជំពូកទី ៧៖ យុទ្ធសាស្រ្ត និងការធានានិរន្តរភាព

៨. ជំពូកទី ៨៖ ការពង្រឹងសមត្ថភាព និងការយល់ដឹង



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

បន្ទាប់មកកញ្ញាក៏បានបង្ហាញពីព័ត៌មានទំនាក់ទំនង ដែលអង្គការ និងអង្គការសហគមន៍មូលដ្ឋានអាចធ្វើការទំនាក់ទំនងសុំព័ត៌មាន និងសួរនូវសំណួរផ្សេងៗទាក់ទងនឹងគោលការណ៍។ Facebook Group កម្រងឯកសារបណ្តុះបណ្តាលគ្រូបង្គោល និងអង្គការសហគមន៍មូលដ្ឋាន និងប្រព័ន្ធរៀនសូត្រតាមអ៊ីនធឺណេត។

(សូមមើលឧបសម្ព័ន្ធ ៣ សម្រាប់បទបង្ហាញអំពីគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន)

## ការពិភាក្សាជាក្រុមតូចៗ ទៅលើការត្រួតពិនិត្យឡើងវិញ និងការចែករំលែកការអនុវត្តន៍មេរៀនកន្លងមកដោយប្រើប្រាស់ឧបករណ៍សកម្មភាព ការឆ្លុះបញ្ចាំង និងការរៀនសូត្រ សម្របសម្រួលដោយកញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

លទ្ធផលសង្ខេបនៃកិច្ចពិភាក្សាមានដូចខាងក្រោម៖

**១. តើអង្គការសហគមន៍មូលដ្ឋានក្នុងវិស័យអ្វី?**

- សហគមន៍នេសាទ
- សហគមន៍មនុស្សចាស់
- លើកកំពស់ការចូលរួមពីមនុស្សចាស់ដែលជាបុរស ស្ត្រី យុវជន កុមារដែលពិការគ្រប់ប្រភេទឲ្យចូលជាសមាជិក សមាគម

**២. តើអង្គការសហគមន៍មូលដ្ឋានបានអនុវត្តចំណុចសំខាន់ៗនៅក្នុងជំពូកនីមួយៗ ដែរឬទេ? បើមានហើយ តើលោកអ្នកយល់ថាចំណុចសំខាន់ៗទាំងនេះមានសារសំខាន់របៀបណា?**

អង្គការសហគមន៍មូលដ្ឋានមួយចំនួនមានការប្រតិបត្តិតាមគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អនៃអង្គការសហគមន៍មូលដ្ឋានបានច្រើន តែអង្គការសហគមន៍មូលដ្ឋានខ្លះមានការប្រតិបត្តិតាមគោលការណ៍ណែនាំនៅមានកម្រិត ហើយមួយចំនួនតូច មិនទាន់ចុះបញ្ជីតាមការណែនាំរបស់ក្រសួង ប៉ុន្តែមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន។

**៣. តើក្នុងការអនុវត្តចំណុចសំខាន់ៗ នៃជំពូកនីមួយៗមានបញ្ហាប្រឈមអ្វីខ្លះ?**

បញ្ហាប្រឈមដែលសហគមន៍បានជួបប្រទះរួមមាន៖

- ធនធានជលផលថយចុះ
- ឧបករណ៍ខុសច្បាប់នៅតែមាន
- ខ្វះទំនាក់ទំនងសហគមន៍ និងស្ថាប័នពាក់ព័ន្ធ
- ខ្វះថវិកាគាំទ្រ
- ខ្វះចំណេះដឹង ជាពិសេសសមាជិក
- ខ្វះការចូលរួម



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

- ចំណេះដឹងរបស់គណៈកម្មការសហគមន៍នៅមានកម្រិត
- សមាជិកមិនសូវបានបញ្ចេញមតិយោបល់ និងពង្រឹងសមត្ថភាព
- ការទទួលខុសត្រូវលើតួនាទីនៅមានកម្រិត
- មានការរើសអើងដល់ជនពិការ និងការរើងអើងពូកបក្សនិយម
- ការអនុវត្តមិនទៅតាមគោលការណ៍ និងលក្ខខណ្ឌន្តិក:
- មិនស្របយោបល់គ្នា គ្មានកិច្ចពិភាក្សា គ្មានអ្នកលើកទឹកចិត្ត
- គ្រប់សេវាកម្មមិនទាន់មានដំណើរបានល្អ
- មិនសូវមានការយកចិត្តទុកដាក់ពីអាជ្ញាធរ និងមន្ត្រីពាក់ពន្ធ័
- មិនមានការឆ្លើយតបទៅនឹងសំណើរដែលសហគមន៍ដាក់ជូន
- សមាជិកបង់វិភាគមិនស្មើគ្នា
- យុទ្ធសាស្ត្រ និងការធានានិរន្តភាពរបស់អង្គការសហគមន៍មូលដ្ឋានមិនទាន់បានច្បាស់លាស់
- សមត្ថភាព និងការយល់ដឹងរបស់គណៈកម្មាការ និងនៅមានកម្រិតនៅឡើយ

**៤. តើគួរធ្វើដូចម្តេចដើម្បីអោយការអនុវត្តរបស់អង្គការសហគមន៍មូលដ្ឋានកាន់តែមានប្រសិទ្ធិភាព?**

ដើម្បីអោយអង្គការសហគមន៍មូលដ្ឋានអនុវត្តការងារកាន់តែមានប្រសិទ្ធិភាពគួរមាន៖

- ជំរុញ និង លើកទឹកចិត្តឲ្យបុរសស្ត្រី យុវជន ជនពិការមានការចូលរួមក្នុងការសហគមន៍
- មានការបណ្តុះបណ្តាលពីការគ្រប់គ្រងដឹកនាំសហគមន៍
- មានកិច្ចសហការណ៍ជាមួយអាជ្ញាធរ និងស្ថាប័នពាក់ពន្ធ័
- ទស្សនកិច្ចយកបទពិសោធន៍ពីសហគមន៍ផ្សេងៗ
- ស្នើរសុំដល់អ្នកជំនាញដើម្បីបណ្តុះបណ្តាលបន្ថែមដល់គណៈកម្មការគ្រប់គ្រង
- បង្កើនការប្រជុំផ្សព្វផ្សាយដល់សមាជិកដែលមានការចូលរួមពីអាជ្ញាធរពាក់ព័ន្ធ

**ការពិភាក្សាជាក្រុមតូចៗ នៅលើ ទីផ្សារ ការធ្វើផែនទីធនធាន និងការបង្កើតសមាគមសម្រាប់អង្គការសហគមន៍មូលដ្ឋាន**

លទ្ធផលសង្ខេបនៃកិច្ចពិភាក្សាមានដូចខាងក្រោម៖

**១. តើលោកអ្នកសង្កេតឃើញថាសហគមន៍របស់លោកអ្នកមានធនធានអ្វីខ្លះដែលអាចធ្វើអាជីវកម្មបាន?**

អង្គការសហគមន៍មូលដ្ឋានដែលបានចូលរួមក្នុងវេទិកាសិក្សាលើកទី ១ នេះ ជាអង្គការសហគមន៍មូលដ្ឋានដែលស្ថិតនៅតាមភូមិភាគពាយព្យ អង្គការទាំងនោះមានធនធាន ដូចជា៖

- ដំណាំកសិកម្ម ឬ ធានាគាស្រូវ (បន្លែ, ស្រូវ, ពោត, ដំឡូង, សណ្តែក....)
- សិប្បកម្ម (ត្បាញកន្ទេល)
- ចិញ្ចឹមសត្វ៖ គោ ជ្រូក មាន់ ទា



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust

- សហគមន៍នេសាទ
- ផលិតផល
- អេកូទេសចរណ៍
- ធនធានធម្មជាតិ (រពាក់ ឬស្សី ផ្តៅ ត្នោតប្រភេទកូនឈើ រំចេក វល្លិ៍ ផ្សិត)

**២. តើធនធានទាំងនោះជាតម្រូវការទីផ្សារដែរឬទេ? តើគួរកែច្នៃរបៀបណាដើម្បីអោយធនធានទាំងនោះកាន់តែមានទីផ្សារ?**

ធនធានទាំងនោះ គឺជាតម្រូវការទីផ្សារចាំបាច់បំផុតនៅក្នុងសហគមន៍។ ហើយដើម្បីកែច្នៃធនធានទាំងនោះកាន់តែមានទីផ្សារ ពួកគាត់អនុវត្តដូចខាងក្រោមៈ

- ការបង្កបង្កើនផលដោយជីធម្មជាតិដូចជា (ជីអាចម៍គោ……)
- កែច្នៃផ្លែឈើទៅជាដំណាប់ផ្សេងៗ
- កែច្នៃជាឧបករណ៍ប្រើប្រាស់ជាច្រើន
- បង្កើនប្រាក់សន្សំ (បង្កើតសេវាវេរលុយ)
- ចិញ្ចឹមសត្វតាមបច្ចេកទេស
- បង្កើតសួនផ្កា និងបន្លែនៅលើទឹក
- រៀនភាសាបរទេសបន្ថែម

**៣. តើប្រជាពលរដ្ឋនៅសហគមន៍របស់លោកអ្នកមានជំនាញក្នុងការកែច្នៃធនធានទាំងនោះដើម្បីធ្វើអាជីវកម្មដែរឬទេ? បើមានគាត់បានធ្វើអ្វី? បើមិនមានតើគួរធ្វើអ្វី? តើមានអង្គការ ឬវិស័យឯកជនណាដែលអាចគាំទ្រ និងផ្តល់ជំនាញទាំងនោះ?**

ប្រជាពលរដ្ឋមិនសូវមានជំនាញក្នុងការកែច្នៃធនធាន ដើម្បីធ្វើអាជីវកម្មទេ។ មានអង្គការពាក់ព័ន្ធ និងមន្ទីកសិកម្មផ្តល់វគ្គបណ្តុះបណ្តាលជំនាញមួយចំនួន ដូចជាជំនាញបច្ចេកទេសកសិកម្មជាដើម។

**៤. តើលោកអ្នកដឹងថាមានសហគមន៍ណាដែលមានធនធានដូច ឬប្រហាក់ប្រហែលធនធានរបស់លោកអ្នកដែរឬទេ? បើមានតើនៅតំបន់ណាខ្លះ?**

សហគមន៍ដែលមានធនធានប្រហាក់ប្រហែលគ្នាមាននៅ ឃុំព្រែកនរិន្ទ, ព្រែកលួង, ព្រែកខ្ពប់ ដូនទ្រី, បាណាកា, តាពូង បរិល,ល្វា និង កំពង់ពោធិ៍។

**៥. តើលោកអ្នកមានទំនាក់ទំនង ឬចងក្រងបណ្តាញជាមួយពួកគាត់យ៉ាងដូចម្តេច? បើមិនទាន់មានតើគួរធ្វើដូចម្តេច?**

សហគមន៍បានចងក្រងបណ្តាញសហគមន៍មួយជាមួយសហគមន៍មួយទៀត សមាគម និងសហព័ន្ធ ប៉ុន្តែមិនទាន់បានចងក្រងជាបណ្តាញផលិតផលកសិកម្មសិប្បកម្ម និង បណ្តាញទីផ្សារនូវឡើយ។

**៦. តើលោកអ្នកមានសំណូមពរអ្វីខ្លះសម្រាប់អង្គការសហការទាំងអស់?**



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476, ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

Accountability គណនេយ្យភាព
GPP 25/08/2015 24/08/2018
Symbol of Trust

សហគមន៍យើងសូមសំណូមពរអង្គការស៊ី ស៊ី ស៊ី និងអង្គការដៃគូទាំងអស់អោយជួយ គាំទ្រ ដូចជា៖

- សូមអង្គការពាក់ព័ន្ធ ជួយសម្របសម្រួលបង្កើតសហព័ន្ធ និងបច្ចេកទេសក្នុងការក្រេងជាបណ្តាញ
- ផ្តល់ជំនួយបច្ចេកទេសផ្នែកកសិកម្ម ផ្នែករកទីផ្សារ ជួយកញ្ចប់ថវិកាសំរាប់បឹងអភិរក្សដែលរីងរាក់នៅរដូវប្រាំង និងសំរាប់ការងារក្នុងសហគមន៍
- ផ្តល់វគ្គបណ្តុះបណ្តាល និង ជំនាញបច្ចេកទេស និងកែច្នៃផលិតផលរបស់សហគមន៍
- បើមានវគ្គ ឬកម្មវិធីបណ្តុះបណ្តាលផ្សេងៗ សុំចូលរួមចាប់ពី២នាក់ឡើងទៅ
- សុំអោយជួយរកទីផ្សារសម្រាប់ផលិតផលរបស់សហគមន៍
- សុំទស្សនកិច្ចសិក្សាតាមបណ្តាខេត្តផ្សេងៗ

## ការពិភាក្សាជាក្រុមតូចៗ ក្នុងការបង្កើតបញ្ជីសំណួរ សម្រាប់ឆ្លុះបញ្ចាំងខ្លួនឯងស្តីពីការប្រតិបត្តិល្អ ធៀបនឹងគោលការណ៍ណែនាំ ស្តីពីការប្រតិបត្តិល្អនៃ អង្គការសហគមន៍មូលដ្ឋាន សម្របសម្រួលដោយលោក ឈន វឌ្ឍន: ប្រធានកម្មវិធីអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ

លទ្ធផលនៃកិច្ចពិភាក្សាមានដូចខាងក្រោម៖

**ជំពូកទី ១៖ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន**

១- អង្គការសហគមន៍មូលដ្ឋានឈ្មោះអ្វី? បង្កើតនៅពេលណា?
២- ចុះកិច្ចព្រមព្រៀងនៅពេលណា?ជាមួយអ្នកណាខ្លះ?
៣- គោលបំណងអ្វី? មានទស្សនៈវិស័យដូចម្តេច? មានបេសកម្មអ្វីខ្លះ?
៤- តើមានគុណតម្លៃឬទេ?
៥- បើមានចំនុចទាំងបីដូចខាងលើ តើសមាជិក និង គណៈកម្មការទាំងអស់យល់ព្រមដែលឬទេ?
៦- តើអង្គការសមាគមន៍មូលដ្ឋានមានការទទួលស្គាល់ជាលាយលក្ខណ៍អក្សរដែរឬទេ?
៧- អង្គការសមាគមន៍មូលដ្ឋានមានសមាសភាពណាខ្លះចូលរួម? មានតួនាទីអ្វីខ្លះ? តើមានបទបញ្ជាផ្ទៃក្នុងដែរឬទេ?

**ជំពូកទី ២៖ ទំនាក់ទំនង កិច្ចសហការ និងការចងក្រងបណ្តាញ**

១- តើសហគមន៍បានចងក្រងបណ្តាញហើយឬនៅ? បណ្តាញជាមួយអ្នកណា?
២- តើយើងត្រូវធ្វើដូចម្តេច?ដើម្បីអោយបណ្តាញរឹងមាំ?
៣- មុនបង្កើតបណ្តាញត្រូវមានការសហការណ៍ជាមួយអ្នកណាខ្លះ?
៤- តើក្រុមបណ្តាញមានតួនាទីអ្វីខ្លះ?
៥- តើក្រុមបណ្តាញមានគោលការណ៍ច្បាស់លាស់ហើយឬនៅ?
៦- បង្កើតបណ្តាញមានគោលការណ៍ផលប្រយោជន៍អ្វីខ្លះ?
៧- តើបណ្តាញទំនាក់ទំនងដោយរបៀបណា?



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃទំនុកចិត្ត

៨- រាល់ការប្រជុំបណ្តាញត្រូវមានអ្នកណាខ្លះចូលរួម?

**ជំពូកទី ៣៖ សមាជិកភាព និងការគ្រប់គ្រងសមាជិក**

១- តើអង្គការមូលដ្ឋានរបស់លោកមានគោលការណ៍ លក្ខន្តិកៈហើយឬទេ?
២- តើសមាជិកភាគច្រើនចូលដោយស្ម័គ្រចិត្ត ឬក៏ដោយបង្ខំ?
៣- តើមានលក្ខណអ្វីខ្លះដែលអាចចូលជាសមាជិកបាន?
៤- តើធ្វើដូចម្តេចដែលបង្កើតគណៈកម្មការគ្រប់គ្រងបាន?
៥- តើសមាជិកសមាជិកាចេញចូលដោយស្ម័គ្រដែរឬទេ?
៦- តើសមាជិកគ្រប់រូបមានតួនាទី និងកាតព្វកិច្ចធ្វើអ្វីខ្លះ?
៧- តើសមាជិកម្នាក់ៗត្រូវបង់ចូលសមាជិកភាពប៉ុន្មាន?
៨- តើសមាជិកបានទទួលផលប្រយោជន៍អ្វីខ្លះពីសហគមន៍?
៩- តើសមាជិកប៉ុន្មាននាក់ឡើងទើបអាចសម្រេច ឬជ្រើសរើសតំណាងចូលរួមក្នុងការការអភិវឌ្ឍ និងថែរក្សាសម្បត្តិរួមក្នុងសហគមន៍?
១០- តើជាទូទៅសហគមន៍មានវិធីសាស្រ្តអ្វីខ្លះដើម្បីកៀគរធនធានក្នុងសហគមន៍?
១១- តើគណៈកម្មការ និងសមាជិកប្រជុំទៀងទាត់ដែរឬទេ?

**ជំពូកទី ៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ**

១- តើមានគោលការណ៍ និងនិតិវិធី គ្រប់គ្រងហិរញ្ញវត្ថុឬអត់?
២- តើមានតួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រងហិរញ្ញវត្ថុឬអត់?
៣- តើមានគោលការណ៍កំណត់រូបិយប័ណ្ណ (ក្រដាស់ប្រាក់រៀល ឬដុល្លារ) និងកំណត់អត្រាប្តូរប្រាក់?
៤- តើមានគោលការណ៍គ្រប់គ្រងហរិញ្ញវត្ថុដែរឬទេ?
៥- តើមាននិតិវិធីនៃប្រត្តិបត្តិការណ៍ហិរញ្ញវត្ថុដែរឬទេ?
៦- តើបានរក្សាទុកឯកសារអោយមានសុវត្ថិភាពដែរឬទេ? និងចែករំលែក ព័ត៌មានទៅសមាជិកដែរឬទេ?
៧- តើមាននិតិវិធីធ្វើលទ្ធកម្ម សំរង់តម្លៃ និងការដេញថ្លៃដែរឬទេ?
៨- តើនរណាខ្លះមានសទ្ធិក្នុងការអនុម័តលើការចំណាយ?
៩- តើមានការគ្រប់គ្រង ចំណូល និងចំណាយដែរឬទេ?
១០- តើមានគោលការណ៍សន្សំ ខ្ចី សងប្រាក់ និង គោលការណ៍បែងចែកភាគហ៊ុន និងការប្រាក់ដែរឬទេ?
១១- តើមានការរៀបចំផែនការថវិកាដែរឬទេ?
១២- តើមានរបាយការណ៍ចំណូល និងចំណាយត្រូវតែកំណត់ពីប្រភពដែលផ្តល់អោយបានច្បាស់លាស់ដែរឬទេ?
១៣- តើមានគោលការណ៍ត្រួតពិនិត្យ ផ្ទៃក្នុងលើការចំណូល និងចំណាយប្រចាំឆ្នាំដោយគណៈកម្មការផ្ទៃក្នុងឯករាជ្យដែរឬទេ?
១៤- តើមានលទ្ធភាពធ្វើសវនកម្ម ដោយសវនករខាងក្រៅដែរឬទេ និងកំណត់អោយច្បាស់លាស់ចាប់ពីចំនួនប៉ុន្មានដុល្លាតាមលទ្ធផលជាក់ស្តែង?
១៣- តើសាវនកម្ម គួរតែមានការកំណត់ និងសំរេចចិត្តរួមគ្នានៅក្នុងអង្គការសហគមន៍មូលដ្ឋានដែរឬទេ?


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476, ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia
Accountability GPP Symbol of Trust 25/08/2015 24/08/2018

**ជំពូកទី ៥៖ គណនេយ្យភាព និងតម្លាភាព**

១- តើគណៈកម្មការមានការទទួលខុសត្រូវលើតួនាទីរបស់ខ្លួនដែរឬទេ?

២- តើរាល់ពេលរៀបចំផែនការ ឬគម្រោងអ្វីមួយមានបានប្រជុំសមាជិកគណៈកម្មការ ទីប្រឹក្សា អង្គការដៃគូរពាក់ពន្ធ័ដែរឬទេ?

៣- តើសមាគមបានបង្កើតបទបញ្ញាផ្ទៃក្នុងស្តីពីទំនាស់ផលប្រយោជន៍របស់គណៈកម្មការ និងសមាជិកដែរឬទេ?

៤- តើគណៈកម្មការមុនពេលរៀបចំប្រជុំអ្វីមួយបានសរសេររបៀបវារៈនៃអង្គប្រជុំ កំណត់របាយការណ៍ និងបញ្ជីស្នាមផ្សេងៗដែរឬទេ?

៥- តើរាល់ពេលចំនូល និងចំណាយបានកត់ត្រាចូលមានក្នុងបញ្ជីមូលនិធិសង្គម ឬបណ្ណ័ចំណាយដែរឬទេ?

៦- តើបានបង្កើតលក្ខន្តិកៈមុនពេលផ្តល់ប្រាក់កម្ចីដល់សមាជិកដែរឬទេ?

៧- តើសហគមន៍ និងគណៈកម្មការបានចំណាយប្រាក់ទៅតាមខ្ទង់ ឬតាមលក្ខន្តិកៈដែរឬទេ?

**ជំពូកទី ៦៖ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ**

ការចូលរួមអនុវត្តត្រួតពិនិត្យ និង វាយតម្លៃ

| សហគមន៍នេសាទ | ១ខែ (អត់អ្នកចូលរួម) | ៣ខែ | ៦ខែ | ១ឆ្នាំ |
|---|---|---|---|---|
| ការគ្រប់គ្រងហិរញ្ញវត្ថុ | | | | |
| សហគមន៍ចាស់ជរា | | | | |
| ឥណទាន | | | | |

**ជំពូកទី ៧៖ យុទ្ធសាស្ត្រ និងការធានានិរន្តរភាព**

១- តើមានការសិក្សាពីឱកាសទីផ្សារហើយឬនៅ?

២- តើមានការរៀបចំផែនការជាក់លាក់ហើយឬនៅ?

៣- តើមានរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុងហើយឬនៅ?

៤- តើចេះពិភាក្សាដោះស្រាយដែរឬទេ?

៥- តើមានដៃគូសហការហើយឬនៅ?

៦- តើបានចូលរួមពីផែនការវិនិយោគឃុំ ឬសង្កាត់ឬនៅ?

៧- តើដឹងពីរបៀបកៀគរធនធានហើយឬនៅ?

៨- តើអ្នកដឹងពីគោលបំណងរួមរបស់សហគមន៍ឬទេ?

៩- តើសេវាកម្មអ្វីខ្លះ ដែលធានាបាននូវនិរន្តភាពរបស់សហគមន៍?



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព GPP 25/08/2015 24/08/2018 Symbol of Trust

**ជំពូកទី ៨៖ ការពង្រឹងសមត្ថភាព និងការយល់ដឹង**

១- តើមានផែនការពង្រឹងសមត្ថភាពដែរឬទេ? បើមាន ជំនាញអ្វីខ្លះ? បើអត់ តើត្រូវការនូវជំនាញអ្វីខ្លះ?
២- តើអ្នកមានតួនាទីជាអ្វី? តើតួនាទីរបស់អ្នកមានការទទួលខុសត្រូវទៅលើអ្វីខ្លះ?
៣- តើយើងមានផែនការចុះត្រួតពិនិត្យតាមដានក្រោយពេលអនុវត្តន៍សកម្មភាពដែរឬទេ?
៤- តើមានអ្នកទុកឯកសារត្រឹមត្រូវដែរឬទេ?
៥- តើមានការប្រជុំប្រចាំខែជាប្រចាំដែរឬទេ?
៦- តើមានធ្វើសន្និបាតប្រចាំឆ្នាំជារៀងរាល់ឆ្នាំដែរឬទេ?

## សុន្ទរកថាបិទ ដោយលោក ឈន វ៉ឌ្ឍន: ប្រធានកម្មវិធីអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវ: ដែលជាតំណាងមកពីអង្គការគណ:កម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

លោកបានថ្លែងអំណរគុណដល់សិក្ខាកាមទាំងអស់ក្នុងការចូលរួម និងពិភាក្សាយ៉ាងផុសផុសក្នុងវេទិកាសិក្សា ហើយសង្ឃឹមថា តំណាងអង្គការសហគមន៍មូលដ្ឋាន ដែលបានចូលរួមក្នុងវេទិកាសិក្សានេះនឹងយកចំណេះដឹងដែលបានសិក្សាយកទៅឆ្លុះបញ្ចាំងការប្រតិបត្តិនៅតាមអង្គការសហគមន៍មូលដ្ឋានរបស់ពួកគាត់ និងសូមជូនពរដល់សិក្ខាកាមទាំងអស់ធ្វើដំណើរត្រលប់ទៅសហគមន៍វិញប្រកបដោយសុវត្ថិភាព។

## មតិត្រលប់ និងសំណូមពរពីសិក្ខាកាម

សំណួរពីរ ដែលអង្គការគ.ស.ក ដែលជាអ្នកផ្តួចផ្តើម និងដឹកនាំរៀបចំវេទិកាសិក្សានេះចង់លឺពីសិក្ខាកាមគឺ តើសិក្ខាកាមរៀនសូត្របានអ្វីខ្លះ និងមានសំណូមពរអ្វីបន្ថែមទៀត

- ចំណេះដឹងដែលសិក្ខាកាមបានរៀនពីវេទិកាសិក្សា

សិក្ខាកាមទាំងអស់បានរៀនសូត្រ យល់ដឹងអំពីជំពូកទាំង ៨ របស់គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ដោយមានការពន្យល់យ៉ាងក្បោះក្បាយពីសំណាក់អ្នកសម្របសម្រួល ជាពិសេសផ្នែកផ្លូវច្បាប់ និងអភិបាលកិច្ចល្អ។ ក្រៅពីនេះសិក្ខាកាមបានយល់ដឹងក្នុងការសិក្សាស្វែងយល់អំពីធនធានដែលមាននៅក្នុងសហគមន៍ និងគិតក្នុងការធ្វើអាជីវកម្មលើធនធានទាំងនោះ។

- សំណូមពរពីសិក្ខាកាម

សិក្ខាកាមមួយចំនួនធំសំណូមពរអោយអង្គការគ.ស.ក ជួយរៀបចំវេទិកាសិក្សាដូចនេះទៀតអោយបានច្រើនដងដើម្បីផ្តល់ឱកាសដល់អង្គការសហគមន៍មូលដ្ឋានជួបជុំគ្នា ចែករំលែកចំណេះដឹង និងបទពិសោធន៍ និងសិក្សាពីគ្នាទៅវិញទៅមក ក្នុងការស្វែងរកដំណោះស្រាយដើម្បីអភិវឌ្ឍសហគមន៍អោយមានការរីកចម្រើន។ សិក្ខាកាមមួយចំនួនសំណូមពរអោយមានការចូលរួមពីសហគមន៍ពី ពីរ ទៅ បីនាក់ ក្នុងវគ្គបណ្តុះបណ្តាលនីមួយៗ។ និងសិក្ខាកាមខ្លះទៀតសំណូមពរអោយអង្គការគ.ស.ក រៀបចំវគ្គបណ្តុះបណ្តាលដល់អង្គការសហគមន៍មូលដ្ឋាននូវជំនាញផ្សេងៗបន្ថែមទៀត ដូចជាការត្រួតពិនិត្យ និងវាយតម្លៃ និងការសរសេររបាយការណ៍ ជាដើម។ សិក្ខាកាមក៏បានសំណូមពរ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

អោយមានការផ្តល់ជូននូវជំនួយខ្នាតតូចដល់អង្គការសហគមន៍មូលដ្ឋានផងដែរ។ និងចុងក្រោយសិក្ខាកាមសំណូមពរអោយមានការប្រជុំឆ្លុះបញ្ចាំងក្នុងចំណោមអង្គការសហគមន៍មូលដ្ឋានអោយបានពីរដងក្នុងមួយឆ្នាំ។

## ឧបសម្ព័ន្ធ

១. បញ្ជីវត្តមានសម្រាប់ទាំងពីរថ្ងៃ

២. ឯកសាទស្សនទាន និងរបៀបវារៈ

៣. បទបង្ហាញអំពីគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust